ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៦...សណន

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១

រាជរដ្ឋាភិបាលបានដាក់ចេញ និងកំពុងអនុវត្តយ៉ាងសកម្មនូវគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដែលត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់មួយ និងជាខ្សែក្រវាត់ការពារទី១ ដើម្បីការពារអាយុជីវិតប្រជាជន ក៏ដូចជាដើម្បីបង្កើតឱ្យបាននូវភាពស៊ាំសហគមន៍ទប់ទល់នឹងមេរោគកូវីដ-១៩ សំដៅឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺនេះតាមគន្លងប្រក្រតីភាពថ្មី។ គិតមកទល់ពេលនេះ, ព្រះរាជាណាចក្រកម្ពុជាសម្រេចបានការចាក់វ៉ាក់សាំងជូនប្រជាជនដែលមានអាយុចាប់ពី ១២ ឆ្នាំឡើងទៅ បានប្រមាណ ៨៩% ធៀបនឹងគោលដៅប្រមាណ ១២ លាននាក់។ យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១ ត្រូវបានរំពឹងថា នឹងអាចបញ្ចប់នៅចុងខែតុលា ឬដើមខែវិច្ឆិកាខាងមុខនេះ មុនផែនការដែលបានគ្រោងទុក។ បន្ថែមពីលើនេះ, រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវ **"គោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ"** ជូនប្រជាជន ដើម្បីធានាឱ្យបាននូវ **"ភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ"** សំដៅទប់ទល់នឹងការវាយលុកនៃមេរោគប្រភេទ Delta ក្នុងសហគមន៍ និងការត្រៀមលក្ខណៈសម្រាប់ការឈានឆ្ពោះទៅកាន់ផែនការបើកដំណើរការប្រទេសពេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។

លើមូលដ្ឋាននៃវឌ្ឍនភាពដ៏ល្អប្រសើរខាងលើនេះ និងក្នុងគោលបំណងបង្កើនល្បឿននៃការចាក់វ៉ាក់សាំងឱ្យបានឆាប់រហ័ស និងអាចឈានទៅបិទបញ្ចប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១ នាពេលដ៏ខ្លីខាងមុខនេះ, **រាជរដ្ឋាភិបាល** សូមធ្វើការណែនាំដល់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស, គណៈអភិបាលរាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ឱ្យយកចិត្តទុកដាក់ក្នុងការពង្រឹងការអនុវត្តការងារមួយចំនួនបន្ថែមទៀត ដូចខាងក្រោម៖

១-គណៈអភិបាលរាជធានី-ខេត្ត ត្រូវប្រមូលផ្តុំការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងលើការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយចាត់ទុកជាការងារស្នូលអាទិភាពខ្ពស់បំផុតរបស់ខ្លួនជាពិសេស ត្រូវសម្រេចឱ្យបានឆាប់រហ័សនូវការចាក់វ៉ាក់សាំងជូនប្រជាជននៅក្នុងមូលដ្ឋានក្រោមសមត្ថកិច្ចរបស់ខ្លួន ដែលជាខ្សែក្រវាត់ការពារទី១ និងជាយុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល ក្នុងសមរភូមិប្រយុទ្ធនឹងជំងឺកូវីដ-១៩។ ទន្ទឹមនេះ គណៈអភិបាលរាជធានី-ខេត្ត ត្រូវរាយការណ៍ប្រចាំថ្ងៃ និងជាប់ជាប្រចាំអំពីវឌ្ឍនភាពនៃការគ្រប់គ្រង និងការអនុវត្តការងារចាក់វ៉ាក់សាំងកូវីដ-១៩ នៅក្នុងមូលដ្ឋានក្រោមសមត្ថកិច្ចរបស់ខ្លួន ជូន

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំង ដើម្បីជាមូលដ្ឋានក្នុងការតាមដាន និងត្រួតពិនិត្យការងារចាក់វ៉ាក់សាំង ដោយប្រើប្រាស់គំរូតារាងព័ត៌មាន ដែលត្រូវបានរៀបចំដោយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស។

២-គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ត្រូវពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យរបស់ខ្លួនលើវឌ្ឍនភាពនៃការអនុវត្តការងារចាក់វ៉ាក់សាំងកូវីដ-១៩ ប្រចាំថ្ងៃ ទាំងសម្រាប់ក្របខណ្ឌរាជធានី-ខេត្តនីមួយៗដាច់ដោយឡែកពីគ្នា ទាំងសម្រាប់ក្របខណ្ឌទូទាំងប្រទេស ព្រមទាំងត្រូវពង្រឹងយន្តការឆ្លើយតបឱ្យបានទាន់ពេលវេលា ទាក់ទងនឹងការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាជនជាក់ស្តែងនៅតាមមូលដ្ឋាន ជាពិសេស ការសម្របសម្រួលក្រុមគ្រូពេទ្យចាក់វ៉ាក់សាំងឱ្យត្រូវទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ និងការធានាផ្គត់ផ្គង់ឱ្យបានទាន់ពេលវេលា និងមិនត្រូវខ្វះវ៉ាក់សាំងជូនដល់បណ្តារាជធានី-ខេត្ត ដើម្បីចាក់ជូនប្រជាជនដោយផ្អែកតាមតម្រូវការជាក់ស្តែងក្នុងភូមិសាស្ត្រនីមួយៗ និងតាមអភិក្រម **"មិនអនុញ្ញាតឱ្យមានវ៉ាក់សាំងដេកក្នុងឃ្លាំង ក្នុងពេលដែលប្រជាជនត្រូវការវ៉ាក់សាំងនោះទេ"**។

៣-គណៈអភិបាលរាជធានី-ខេត្ត ត្រូវរៀបចំធ្វើបច្ចុប្បន្នកម្មឡើងវិញឱ្យបានច្បាស់លាស់ និងឆាប់រហ័សអំពីចំនួនប្រជាជនជាក់ស្តែងនៅមូលដ្ឋានដែលត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ជាពិសេស នៅកម្រិតថ្នាក់ឃុំ-សង្កាត់ និងញែកចេញចំនួនប្រជាជនចំណាកស្រុក ដែលអាចទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ នៅទីកន្លែងផ្សេង ដើម្បីមានមូលដ្ឋានច្បាស់លាស់ ក្នុងការកែសម្រួលផែនការចាក់វ៉ាក់សាំងដោយផ្អែកតាមចំនួនប្រជាជនជាក់ស្តែងនៅក្នុងមូលដ្ឋាន ក៏ដូចជាឈានទៅសម្រេចបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅមូលដ្ឋាននោះ។ ប៉ុន្តែ មុននឹងសម្រេចបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងនៅមូលដ្ឋាននីមួយៗ និងចល័តទៅកាន់ទីកន្លែងផ្សេងទៀត, ក្រុមការងារយុទ្ធនាការចាក់វ៉ាក់សាំងនៅតាមមូលដ្ឋាននីមួយៗ ត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការត្រៀមបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នេះ និងត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីសម្រេចបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងនៅទីតាំងមូលដ្ឋាននោះ។ ទន្ទឹមនេះ បន្ទាប់ពីការបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមមូលដ្ឋាននីមួយៗ និងដើម្បីធានាដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩ នេះ ឱ្យបានគ្រប់គ្នាជូនដល់ប្រជាជនដែលមានលក្ខណៈសម្បត្តិអាចចាក់វ៉ាក់សាំងបាន, គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និងគណៈអភិបាលរាជធានី-ខេត្ត ត្រូវសហការគ្នាកំណត់អំពីទីតាំងសម្រាប់ការផ្តល់សេវាចាក់វ៉ាក់សាំងជូនដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យបង្អែកក្រុង-ស្រុក-ខណ្ឌ ឬនៅតាមមណ្ឌលសុខភាព (ផ្អែកតាមស្ថានភាពនៃភូមិសាស្ត្រជាក់ស្តែងនីមួយៗ) និងត្រូវជូនដំណឹងជាសាធារណៈ ដើម្បីអនុញ្ញាតឱ្យប្រជាជនដែលមិនទាន់បានទទួលការចាក់វ៉ាក់សាំង អាចទៅទទួលការចាក់វ៉ាក់សាំងនេះបាននៅតាមទីតាំងកំណត់នោះ។

៤-សម្រាប់ក្របខណ្ឌទូទាំងប្រទេស, ផ្អែកលើមូលដ្ឋាននៃវឌ្ឍនភាពនៃការចាក់វ៉ាក់សាំងលើចំនួនជាក់ស្តែងនៃប្រជាជននៅមូលដ្ឋាន និងលទ្ធផលនៃការធ្វើបច្ចុប្បន្នកម្មចំនួនប្រជាជននៅតាមបណ្តារាជធានី-ខេត្ត, គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ត្រូវធ្វើការបូកសរុប និងវាយតម្លៃ ដើម្បីស្នើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាល ក្នុងការបិទបញ្ចប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១ តាមរាជធានី-ខេត្តនីមួយៗជាបន្តបន្ទាប់រហូតដល់ការបិទបញ្ចប់យុទ្ធនាការនេះក្នុងក្របខណ្ឌទូទាំងប្រទេស ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់រាជរដ្ឋាភិបាលធ្វើការសម្រេចចិត្តក្នុងការអនុវត្តផែនការ

នានាក្នុងជំហានបន្តបន្ទាប់ទៀត។ បន្ថែមពីនេះ បន្ទាប់ពីការសម្រេចបិទបញ្ចប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១, គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ដោយសហការជាមួយគណៈអភិបាលរាជធានី-ខេត្ត ត្រូវបន្តរៀបចំឱ្យមានទីតាំងសម្រាប់ការផ្តល់សេវាចាក់វ៉ាក់សាំងជូនដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យបង្អែកក្រុង-ស្រុក-ខណ្ឌ ឬនៅតាមមណ្ឌលសុខភាព ឬតាមទីតាំងផ្សេងទៀត (ផ្អែកតាមស្ថានភាពនៃភូមិសាស្ត្រជាក់ស្តែងនីមួយៗ) និងត្រូវជូនដំណឹងជាសាធារណៈ ដើម្បីអនុញ្ញាតឱ្យប្រជាជនដែលមិនទាន់បានទទួលការចាក់វ៉ាក់សាំង ដោយមូលហេតុផ្សេងៗ អាចទៅទទួលការចាក់វ៉ាក់សាំងនេះបាន។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស គណៈអភិបាលរាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសៅរ៍ ៦រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល៖**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ